ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបប្រតិភូក្រុមហ៊ុន **JWD Group Co,Ltd**



នៅព្រឹកថ្ងៃទី៣១ ខែ សីហា ឆ្នាំ២០១៥ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបប្រតិភូក្រុមហ៊ុន **JWD Group Co,Ltd** ដឹកនាំដោយលោក **CHARVANIN BUNDITKITSADA** ប្រធានអគ្គនាយកក្រុមហ៊ុន **JWD Group Co,Ltd** ដើម្បីពិភាក្សាការងារ នៅទីស្តីការក្រសួង ។



លោក **CHARVANIN BUNDITKITSADA** ប្រធានអគ្គនាយកក្រុមហ៊ុន **JWD Group Co,Ltd** បានជម្រាបពីគោលបំណងនៃជំនួបពិភាក្សា គឺដើម្បីអធិប្បាយជូនអំពីសកម្មភាព និងកម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុន ដែលមានសេវាកម្មបម្រើដូចជា៖ ផ្នែកគ្រប់គ្រងឃ្លាំង–ដឹកជញ្ជូន –គ្រប់គ្រងព័ត៌មាន និងកំណត់ត្រា–ជួលឃ្លាំង–សេវាកម្មបន្លាស់ទី (Moving) –ដំណោះស្រាយបច្ចេកវិទ្យាព័ត៌មាន និងផ្សេងៗ ។ ប៉ុន្តែអ្វីដែលក្រុមហ៊ុនបានផ្តោតជាសំខាន់ក្នុងកិច្ចប្រជុំនោះ គឺ សេវាគ្រប់គ្រងសារធាតុគីមីគ្រោះថ្នាក់ តាមរយៈការដឹកជញ្ជូន–ការត្រួតពិនិត្យ–ការស្តុកទុក និងវិធានការថែទាំ ជៀសវាងការបង្កគ្រោះថ្នាក់ជាយថាហេតុ ដែលក្រុមហ៊ុនបានលើកឧទាហរណ៍ ដូចជា ៖ នៅពេលថ្មីៗនេះ ការបែកធ្លាយផ្ទុះសារធាតុគីមី នៅទីក្រុង Tiajin នៃប្រទេសចិនកាលពីថ្ងៃ ១២ ខែ សីហា ឆ្នាំ២០១៥ និងការបែកធ្លាយសារធាតុគីមីកន្លងទៅនៅប្រទេសថៃ និងប្រទេសមួយចំនួនទៀត ដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន និងជីវិតមនុស្ស សត្វ ។ កត្តានេះ ក៏ធ្វើឱ្យប្រទេសជាច្រើនលើពិភពលោក មានការកែប្រែខ្លះ នូវច្បាប់ស្តីពីការគ្រប់គ្រងសារធាតុគីមីគ្រោះថ្នាក់ ដើម្បីធានាប្រសិទ្ធិភាព និង សុវត្ថិភាពជាងមុន ។ ទាក់ទងបរិបទនេះ តំណាងក្រុមហ៊ុន **JWD Group** ក៏បានផ្តល់អនុសាសន៍ដល់ប្រទេសកម្ពុជា ក្នុងការបង្កើតឱ្យមានច្បាប់ស្តីពីការគ្រប់គ្រងសារធាតុគីមីគ្រោះថ្នាក់នេះផងដែរ ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និងវាយតម្លៃខ្ពស់ ចំពោះស្នាដៃ និងសមិទ្ធិផលនានា ដែលក្រុមហ៊ុន **JWD Group** សម្រេចបាន ហើយ ឯកឧត្តម បានស្វាគមន៍ចំពោះបំណងវិនិយោគរបស់ក្រុមហ៊ុននៅកម្ពុជា ។ ទាក់ទងនិងសេវាគ្រប់គ្រងសារធាតុគីមីគ្រោះថ្នាក់ ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានចាត់ទុកជាកត្តាសំខាន់ ពីព្រោះមានបទពិសោធន៍កើតឡើងជាច្រើនហើយ នៅជុំវិញពិភពលោក ។ ដូច្នេះឯកឧត្តមស្នើឱ្យក្រុមហ៊ុនផ្តល់បទពិសោធន៍ និងចែករំលែកចំណេះដឹងដល់កម្ពុជា តាមរយៈរៀបចំសិក្ខាសាលា ដោយអញ្ជើញក្រសួងពាក់ព័ន្ធចូលរួមពីព្រោះការគ្រប់គ្រងសារធាតុគីមីគ្រោះថ្នាក់នេះ មានទាក់ទិននិងស្ថាប័នពាក់ព័ន្ធជាច្រើនទៀត ហើយឯកឧត្តម ក៏គាំទ្រឱ្យមានការបង្កើតច្បាប់ស្តីពីការគ្រប់គ្រងសារធាតុគីមីគ្រោះថ្នាក់ផងដែរ ។

ទាក់ទង និង ការដឹកជញ្ជូនសារធាតុគីមីគ្រោះថ្នាក់ ឆ្លងកាត់កំពង់ផែផ្លូវទឹក និងផ្លូវគោក ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានផ្តល់គំនិតដល់អ្នកវិនិយោគថា៖ គឺត្រូវរកទីតាំងកំពង់ផែណា ដែលនៅឃ្លាតឆ្ងាយពីទីប្រជុំជន និងប្រភពទឹក ។ ក្នុងនោះ ការដឹកជញ្ជូនពីប្រទេសថៃ អាចតម្រូវឱ្យនៅទីក្រុងប៉ោយប៉ែត ពីវៀតណាម នៅទីក្រុង បាវិត និងកំពង់ផែផ្លូវទឹក កំណត់យកខេត្តព្រះសីហនុ ជាការប្រសើរ ។ ជាមួយគ្នានេះ ក៏ត្រូវមានយន្តការត្រួតពិនិត្យ និងទប់ស្កាត់ការនាំចូលសារធាតុគីមីគ្រោះថ្នាក់ ក្នុងចំនួនវេចខ្ចប់តិចតួច និងការរត់ពន្ធ ជាដើម ។